# ម៉ាស៊ីនភ្លើងបំប្លែងចរន្តអគ្គិសនីពហុមុខងារ D14000iE

## សៀវភៅណែនាំអ្នកប្រើប្រាស់

v1.0 2025.06



ឯកសារនេះត្រូវបានរក្សាសិទ្ធិគ្រប់យ៉ាងដោយ DJI។ អ្នកមិនមានសិទ្ធិប្រើប្រាស់ ឬអនុញ្ញាតឱ្យអ្នកដទៃប្រើប្រាស់ឯកសារ ឬផ្នែកណាមួយនៃឯកសារដោយការផលិតឡើងវិញ ផ្ទេរ ឬលក់ឯកសារនោះទេ លុះត្រាតែមានការអនុញ្ញាតពី DJI។ អ្នកប្រើគួរតែយោងទៅលើឯកសារនេះ និងខ្លឹមសាររបស់វាជាការណែនាំដើម្បីដំណើរការផលិតផល DJI។ ឯកសារនេះមិនគួរប្រើប្រាស់សម្រាប់គោលបំណងផ្សេងទៀតទេ។

ករណីមានភាពខុសគ្នាក្នុងចំណោមកំណែផ្សេងៗគ្នា ត្រូវយកកំណែជាភាសាអង់គ្លេសជាគោល។

**ការស្វែងរកពាក្យគន្លឹះ**

ស្វែងរកពាក្យគន្លឹះដូចជា "ថ្ម" និង "ដំឡើង" ដើម្បីស្វែងរកប្រធានបទ។ ប្រសិនបើអ្នកកំពុងប្រើប្រាស់ Adobe Acrobat Reader ដើម្បីអានឯកសារនេះ សូមចុច Ctrl+F នៅលើ Windows ឬ Command+F នៅលើ Mac ដើម្បីចាប់ផ្ដើមការស្វែងរក។

**ការរុករកទៅកាន់ប្រធានបទ**

ពិនិត្យមើលទៅលើបញ្ជីពេញលេញនៃប្រធានបទនៅក្នុងតារាងមាតិកា។ សូមចុចលើប្រធានបទដើម្បីស្វែងរកទៅលើផ្នែកនោះ។

**ការបោះពុម្ពឯកសារនេះ**

ឯកសារនេះគាំទ្រការបោះពុម្ពផ្សាយដែលមានគុណភាពច្បាស់ល្អ។


© 2025 DJI រក្សាសិទ្ធិគ្រប់យ៉ាង។

# តារាងមាតិកា


**1 ការដំឡើងដំបូង 4**

**2 ទិដ្ឋភាពទូទៅ 6**

2.1 ម៉ាស៊ីនភ្លើង 6

2.2 ផ្ទាំងប្រតិបត្តិការ 7

2.3 LED ស្ថានភាព 8

**3 ចាប់ផ្ដើម 10**

3.1 ការចាក់ប្រេងម៉ាស៊ីន 10

3.2 ការចាក់បំពេញឥន្ធនៈ 10

**4 ការត្រួតពិនិត្យមុនពេលប្រតិបត្តិការ 11**

4.1 ចំណុចត្រូវត្រួតពិនិត្យទូទៅ 11

4.2 ចំណុចត្រូវត្រួតពិនិត្យសំខាន់ៗ 11

**5 ការប្រើប្រាស់ម៉ាស៊ីនភ្លើង 12**

5.1 ការបើកដំណើរការ និងការធ្វើបច្ចុប្បន្នភាពកម្មវិធីបង្កប់ 12

5.2 ការបញ្ឆេះម៉ាស៊ីនភ្លើង 12

5.3 ការពន្លត់ម៉ាស៊ីនភ្លើង 13

5.4 ការប្រើប្រាស់ថ្មហោះហើរឆ្លាតវៃជាប្រភពថាមពលខាងក្រៅ 13

**6 ការរក្សាទុក 14**

**7 ការដឹកជញ្ជូន 15**

**8 ការថែទាំ 16**

8.1 ការជូនដំណឹងអំពីសុវត្ថិភាពថែទាំ 16

8.2 កាលវិភាគថែទាំ 16

8.3 ការពិនិត្យមើលកម្រិតប្រេងម៉ាស៊ីន 18

8.4 ការប្ដូរប្រេងម៉ាស៊ីន 18

8.5 ការពិនិត្យ និងសម្អាតផ្នែកតម្រងខ្យល់ 19

8.6 លាងសម្អាតឧបករណ៍ទប់ផ្កាភ្លើង 20

8.7 ការពិនិត្យ សម្អាត និងប្ដូរប៊ូស៊ី 20

**9 លក្ខណៈបច្ចេកទេស 22**


© 2025 DJI រក្សាសិទ្ធិគ្រប់យ៉ាង។ 

# 1 ការដំឡើងដំបូង

1. ដោះជើងទម្រដើមចេញ។

    a. ប៊ូឡុង

    b. ជើងទម្រ

    c. ក្បាលឡោស៊ី

- ប្រសិនបើចាំបាច់ត្រូវផ្លាស់ទីម៉ាស៊ីនភ្លើងលើដីមិនស្មើ យើងសូមណែនាំឱ្យដោះជើងទម្រដើមពីរនៅជិតបំពង់ស៊ីម៉ាំង។ រំលងជំហាននេះ ប្រសិនបើមិនចាំបាច់។
- ដាក់ដុំជ័រ ឬឈើក្រោមម៉ាស៊ីនភ្លើងដែលមានកម្ពស់ដូចគ្នានឹងជើងទម្រ ដើម្បីជៀសវាងផ្អៀងម៉ាស៊ីនភ្លើងទៅក្រោយ នៅពេលជើងទម្រត្រូវបានដោះចេញ។




2. ការដំឡើងកង់រុញ។

    a. ដងបង្វិលកង់

    b. ទ្រនាប់ខ្ចៅ

    c. ដែកខ្ទាស់




3. ដំឡើងដងកាន់។

    a. ដែកខ្ទាស់

    b. ដង

 © 2025 DJI រក្សាសិទ្ធិគ្រប់យ៉ាង។

c. ប៊ូឡុង



# 2 ទិដ្ឋភាពទូទៅ

## 2.1 ម៉ាស៊ីនភ្លើង

- រូបភាពគឺសម្រាប់ជាឯកសារយោងតែប៉ុណ្ណោះ ហើយអាចខុសពីផលិតផលពិតប្រាកដ។




1. ធុងឥន្ធនៈ
2. គម្របធុងឥន្ធនៈ
3. ឧបករណ៍វាស់កម្រិតប្រេង
4. តួ
5. ដង
6. ស្ថានភាព LEDs
7. ផ្ទាំងប្រតិបត្តិការ
8. ខ្សែសាក
9. ឯកតាគ្រប់គ្រង
10. ជើងទម្រ
11. កង់រុញ
12. គម្របកង្ហារ
13. តម្រងខ្យល់
14. ឧបករណ៍ទប់ផ្កាភ្លើង


© 2025 DJI រក្សាសិទ្ធិគ្រប់យ៉ាង។

15. គម្រងសំបុកស៊ីម៉ាំង
16. ចង្កឹះជ្រលក់មើលកម្រិតប្រេងម៉ាស៊ីន
17. ប៊ូស៊ី
18. ទុយោបង្ហូរប្រេងម៉ាស៊ីន
19. អង្គភាពចាក់ប្រេងឥន្ធនៈអេឡិចត្រូនិក
20. បំពង់ប្រេងសម្ពាធខ្ពស់។

## 2.2 ផ្ទាំងប្រតិបត្តិការ




1. **កុងតាក់បិទបើកម៉ាស៊ីន**

   សម្រាប់ប្រើប្រាស់ដើម្បីបញ្ឆេះ ឬពន្លត់ម៉ាស៊ីនភ្លើង។

2. **រន្ធ USB-C**

   ភ្ជាប់តេឡេបញ្ជា ដើម្បីធ្វើបច្ចុប្បន្នភាពកម្មវិធីបង្កប់ និងនាំចេញកំណត់ហេតុ។

3. **កន្លែងដោតឌុយប្រើចរន្តឆ្លាស់***

   កន្លែងដោតឌុយនេះគឺបំពេញតាមចំណាត់ថ្នាក់ការការពារ IP44។ ត្រូវប្រាកដថាបានដំឡើងឡើងវិញ និងចងរឹតគម្រប កន្លែងដោតឌុយនៅពេលមិនប្រើប្រាស់។

4. **ប៉ូលដី**

   ប្រើប្រាស់ខ្សែដី ហើយភ្ជាប់ចុងម្ខាងទៅនឹងប៉ូលដី និងចុងម្ខាងទៀតទៅនឹងដី។ ការភ្ជាប់ខ្សែដីបានត្រឹមត្រូវអាចជួយបង្ការ ការឆក់អគ្គិសនីក្នុងករណីដែលឧបករណ៍មានបញ្ហា។

* ថាមពល AC ដែលបានវាយតម្លៃខុសគ្នាទៅតាមប្រទេស និងតំបន់ផ្សេងៗគ្នា។ ពិគ្រោះជាមួយផ្នែកជំនួយផ្លូវការ ឬអ្នកចែកចាយដែលមានអាជ្ញាបណ្ណ ដើម្បីទទួលបានព័ត៌មានលម្អិត។ ប្រេកង់ថាមពល AC អាចត្រូវបានកំណត់រចនាសម្ព័ន្ធទៅជា 50 Hz ឬ 60 Hz នៅក្នុងកម្មវិធី។ ដើម្បីធានានូវការប្រតិបត្តិការដែលមានសុវត្ថិភាពនៃឧបករណ៍អគ្គិសនីរបស់អ្នក និងការពារការខូចខាតដែលអាចកើតមាន សូមជ្រើសរើសប្រេកង់ដែលសមស្របតាមលក្ខខណ្ឌតម្រូវប្រេកង់នៃឧបករណ៍អគ្គិសនី។

© 2025 DJI រក្សាសិទ្ធិគ្រប់យ៉ាង។

## 2.3 LED ស្ថានភាព




| 1. ពន្លឺ LED ស្ថានភាពនៃបណ្តាញសាកថ្ម | |
|---|---|
| ភ្លើងលឿងដិត | បានភ្ជាប់ថ្ម និងអាចសាកថ្មបានហើយ |
| លោតភ្លើងពណ៌បៃតងម្តងជាបន្តបន្ទាប់ | សាកថ្ម |
| ភ្លើងបៃតងដិត | បានសាកពេញ |
| ភ្លើងពណ៌លឿងលោតភ្លឹបភ្លែតៗម្តងជាប់គ្នា | ការព្រមានសម្រាប់ថ្ម/បណ្តាញសាក |
| ភ្លើងពណ៌ក្រហមលោតភ្លឹបភ្លែតៗម្តងជាប់គ្នា | កំហុសបណ្តាញថ្ម/សាក |
| **2. LED ស្ថានភាពនៃម៉ូឌុល AC** | |
| លឿងដិត | ម៉ូឌុល AC អាចប្រើបានហើយ |
| លោតភ្លើងពណ៌បៃតងម្តងជាបន្តបន្ទាប់ | ម៉ូឌុល AC កំពុងប្រើប្រាស់ |
| លោតភ្លើងពណ៌លឿងម្តងជាបន្តបន្ទាប់ | ការព្រមានសម្រាប់ម៉ូឌុល AC |
| លោតភ្លើងពណ៌ក្រហមម្តងជាបន្តបន្ទាប់ | បញ្ហាម៉ូឌុល AC |
| **3. LED ស្ថានភាពនៃម៉ាស៊ីនភ្លើង** | |

 © 2025 DJI រក្សាសិទ្ធិគ្រប់យ៉ាង។

| | |
|---|---|
| លឿងព្រិចៗបួនដង បន្តបន្ទាប់គ្នា | ម៉ាស៊ីនភ្លើងមិនត្រូវបានបើកដំណើរការទេ |
| លោតភ្លើងពណ៌លឿង ម្តងជាបន្តបន្ទាប់ | ការព្រមានសម្រាប់ម៉ាស៊ីនភ្លើង |
| លោតភ្លើងពណ៌ក្រហម ម្តងជាបន្តបន្ទាប់ | បញ្ហាម៉ាស៊ីនភ្លើង |
| លោតភ្លើងពណ៌ក្រហម បួនដងជាបន្តបន្ទាប់ | ត្រូវការថែទាំម៉ាស៊ីនភ្លើង |

⚠ 

- ប្រសិនបើភ្លើង LED ស្ថានភាពណាមួយលោតភ្លើងដែលបញ្ជាក់អំពីការព្រមាន ឬបញ្ហា ឬជំរុញឱ្យធ្វើការថែទាំ សូមភ្ជាប់តេឡេបញ្ជាទៅផលិតផល ដើម្បីពិនិត្យមើលលម្អិត។
- ប្រសិនបើផ្នែកណាមួយនៃផលិតផលមិនប្រក្រតី ឬមានការខូចខាត យើងសូមណែនាំឱ្យទាក់ទងទៅកាន់ផ្នែកជំនួយផ្លូវការ ឬឈ្មួញដែលមានការអនុញ្ញាត ដើម្បីជួសជុល ឬប្តូរផ្នែកនោះចេញ។

© 2025 DJI រក្សាសិទ្ធិគ្រប់យ៉ាង។ 

# 3 ចាប់ផ្ដើម

## 3.1 ការចាក់ប្រេងម៉ាស៊ីន

⚠ • ម៉ាស៊ីនមិនទាន់ត្រូវបានចាក់ប្រេងម៉ាស៊ីនចូលនោះទេមុនពេលចាកចេញពីរោងចក្រ។ សូមចាក់ប្រេងម៉ាស៊ីន SJ 10W-40 (ឬប្រេងប្រភេទដូចគ្នានេះ) មុនពេលប្រើប្រាស់។

ដាក់ម៉ាស៊ីនភ្លើងនៅលើផ្ទៃរាបស្មើ និងមានលំនឹង មួលបើកចង្កឹះជ្រលក់មើលកម្រិតប្រេង ចាក់ប្រេងចូលក្នុងម៉ាស៊ីនដល់ត្រឹមសមត្ថភាពផ្ទុកដែលបានកំណត់ ហើយមួលបិទចង្កឹះវិញ។

## 3.2 ការចាក់បំពេញឥន្ធនៈ

⚠ • កុំបើកម៉ាស៊ីនភ្លើងមុនពេលចាក់ប្រេងម៉ាស៊ីន ឬសាំង។ បើមិនដូច្នោះទេស្នប់ឥន្ធនៈអេឡិចត្រូនិកអាចខូច។
• សូមកុំចាក់ឥន្ធនៈដល់ពេញហៀរ។ ការកំពប់អាចនាំឱ្យមានអគ្គិភ័យ ឬការផ្ទុះ។

ឥន្ធនៈគឺមានភាពងាយឆាបឆេះ និងផ្ទុះកម្រិតខ្ពស់។ សូមអនុវត្តតាមការណែនាំប្រើប្រាស់ឱ្យបានម៉ឺងម៉ាត់។ មុនពេលចាក់បំពេញឥន្ធនៈទៅក្នុងម៉ាស៊ីនភ្លើង សូមផ្ដាច់ចរន្តអគ្គិសនីពីវា និងរង់ចាំរហូតដល់វាត្រជាក់ទាំងស្រុង។

1. មួលបើកគម្របធុងឥន្ធនៈ និងចាក់បំពេញឥន្ធនៈទៅក្នុងធុងឥន្ធនៈដោយប្រើប្រភេទឥន្ធនៈដែលត្រូវបានណែនាំត្រឹមកម្រិតសមត្ថភាពផ្ទុកដែលត្រូវបានវាយតម្លៃ ដោយយោងទៅតាមឧបករណ៍វាស់កម្រិតប្រេង។*
2. មួលបិទគម្របធុងឥន្ធនៈវិញបន្ទាប់ពីការចាក់បំពេញឥន្ធនៈ។ ប្រើប្រាស់កន្សែងស្ងួតដើម្បីជូតប្រសិនបើមានប្រេងឥន្ធនៈកំពប់។

* ប្រភេទប្រេងឥន្ធនៈដែលបានណែនាំគឺជាប្រេងឥន្ធនៈគ្មានជាតិសំណ ដែលមានការវាយតម្លៃអុកតានអប្បបរមា 91 RON និងមានអេតាណុលតិចជាង 10% តាមកម្រិត។ ប្រសិនបើប្រើម៉ាស៊ីនភ្លើងនៅប្រេស៊ីល ប្រភេទប្រេងឥន្ធនៈដែលបានណែនាំគឺជាប្រេងឥន្ធនៈគ្មានជាតិសំណ ដែលមានការវាយតម្លៃអុកតានអប្បបរមា 91 RON និងមានអេតាណុល 27% តាមកម្រិត។

 © 2025 DJI រក្សាសិទ្ធិគ្រប់យ៉ាង។

# 4 ការត្រួតពិនិត្យមុនពេលប្រតិបត្តិការ

ពិនិត្យលក្ខខណ្ឌនៃម៉ាស៊ីនភ្លើងមុនពេលប្រតិបត្តិការនីមួយៗ។ សូមប្រាកដថាម៉ាស៊ីនភ្លើងត្រូវបានដាក់នៅកន្លែងមានស្ថិរភាព ហើយកុំងតាក់បិទបើកម៉ាស៊ីននៅក្នុងទីតាំងបិទ។

## 4.1 ចំណុចត្រូវត្រួតពិនិត្យទូទៅ

- ពិនិត្យមើលថាតើមានប្រេងម៉ាស៊ីនកំពប់ ឬមានឥន្ធនៈនៅជុំវិញ ឬក្រោមម៉ាស៊ីនភ្លើងដែរឬទេ។
- យកសម្ភារៈងាយឆាបឆេះចេញពីបរិវេណជុំវិញ ជាពិសេសជុំវិញសំបុកស៊ីម៉ាំង និងគម្របកង្ហារ។
- ជួសជុល ឬផ្លាស់ប្តូរផ្នែកដែលមានច្រែះ បាក់បែក ខូចខាត ខូចទ្រង់ទ្រាយ ឬរលុង។
- ពិនិត្យមើលថាតើគម្របសំបុកស៊ីម៉ាំង និងគម្រងកង្ហារត្រូវបានដំឡើងត្រូវកន្លែងបានជាប់ល្អដែរឬទេ និងថាតើក្បាលឡោស៊ី ប៊ូឡុង និងវីសត្រូវបានរឹតជាប់ដែរឬទេ។

## 4.2 ចំណុចត្រូវត្រួតពិនិត្យសំខាន់ៗ

- ពិនិត្យមើលកម្រិតឥន្ធនៈ៖ ចាក់បំពេញឥន្ធនៈទៅក្នុងធុងឥន្ធនៈមុនពេលប្រតិបត្តិការ ដើម្បីកាត់បន្ថយឱកាសដែលប្រតិបត្តិការត្រូវបានរំខានដោយសារតែកម្រិតឥន្ធនៈទាប។
- ពិនិត្យមើលកម្រិតប្រេងម៉ាស៊ីន៖ ការដំណើរការជាមួយប្រេងម៉ាស៊ីនដែលមានកម្រិតទាប នឹងបណ្តាលឱ្យម៉ាស៊ីនខូច។ នៅពេលដែលបរិមាណប្រេងម៉ាស៊ីនធ្លាក់ចុះក្រោមកម្រិតសុវត្ថិភាព នោះសេនស័រចាប់ប្រេងម៉ាស៊ីនដែលត្រូវបានបំពាក់នៅខាងក្នុងនឹងបញ្ឈប់ម៉ាស៊ីនលែងឱ្យដំណើរការ។ ពិនិត្យមើលកម្រិតប្រេងម៉ាស៊ីនមុនពេលប្រតិបត្តិការម្តងៗដើម្បីចៀសវាងភាពរអាក់រអួលដែលបណ្តាលមកពីបញ្ហាដែលកើតឡើងភ្លាមៗមិនបានរំពឹងទុក។
- ពិនិត្យមើលផ្នែកតម្រងអេប៉ុងនៃតម្រងខ្យល់៖ ផ្នែកតម្រងអេប៉ុងដែលកខ្វក់កាត់បន្ថយខ្យល់ដែលចូលទៅក្នុងកន្លែងចាក់ប្រេងអេឡិចត្រូនិក ដែលកាត់បន្ថយសមត្ថភាពរបស់ម៉ាស៊ីនភ្លើង។

© 2025 DJI រក្សាសិទ្ធិគ្រប់យ៉ាង។ 

# 5 ការប្រើប្រាស់ម៉ាស៊ីនភ្លើង

## 5.1 ការបើកដំណើរការ និងការធ្វើបច្ចុប្បន្នភាពកម្មវិធីបង្កប់

ត្រូវតែបើកដំណើរការផលិតផល មុនពេលប្រើប្រាស់ជាលើកដំបូង។ បន្ទាប់ពីភ្ជាប់តេឡេបញ្ជាទៅផលិតផល សូមដំណើរការកម្មវិធី DJI Agras នៅលើតេឡេបញ្ជា ហើយចុច**ការគ្រប់គ្រងឧបករណ៍ >** ◌ **ឧបករណ៍សាក** ដើម្បីបើកដំណើរការផលិតផល។ អនុវត្តតាមសេចក្តីណែនាំលើអេក្រង់ ដើម្បីធ្វើដំឡើងកំណែកម្មវិធីបង្កប់ នៅពេលមានកម្មវិធីបង្កប់ថ្មី។




## 5.2 ការបញ្ឆេះម៉ាស៊ីនភ្លើង

⚠ • ប្រសិនបើម៉ាស៊ីនភ្លើងមិនអាចបញ្ឆេះបាន សូមភ្ជាប់វាទៅតេឡេបញ្ជា ដើម្បីមើលព័ត៌មានបន្ថែម។

• ប្រសិនបើមានឧបករណ៍អេឡិចត្រូនិកដែលដំណើរការបានភ្ជាប់ទៅឌុយ AC ពេលកំពុងសាកថ្ម សមត្ថភាពសាកថ្មសម្រាប់ថ្មនឹងធ្លាក់ចុះទៅតាមនោះ ហើយរយៈពេលសាកថ្មនឹងត្រូវបានពន្យារ។

1. សូមកុំភ្ជាប់ឧបករណ៍អគ្គិសនីណាមួយមុនពេលបញ្ឆេះម៉ាស៊ីនភ្លើង។
2. ត្រូវប្រាកដថាម៉ាស៊ីនត្រូវបានចាក់ប្រេងម៉ាស៊ីនរួច ហើយនៅក្នុងធុងឥន្ធនៈត្រូវមានឥន្ធនៈមិនតិចជាង 1លីត្រ។
3. ភ្ជាប់ខ្សែសាកថ្មទៅកាន់ថ្មដ្រូនវៃឆ្លាតដែលត្រូវបានបិទ។ ចុច ហើយបន្ទាប់មកចុចប៊ូតុងបិទបើកនៅលើថ្មឱ្យជាប់ ដើម្បីបើកថ្ម។
4. រំកិលកុងតាក់បិទបើកម៉ាស៊ីនទៅរកទីតាំងបញ្ឆេះ ហើយចុចឱ្យជាប់យ៉ាងហោចណាស់ 3 វិនាទី ហើយលែង។ កុងតាក់បិទបើកម៉ាស៊ីននឹងត្រឡប់ទៅទីតាំងបើកវិញ ហើយម៉ាស៊ីនភ្លើងនឹងបញ្ឆេះដោយស្វ័យប្រវត្តិ។
5. ម៉ាស៊ីនភ្លើងចាប់ផ្តើមសាកថ្ម។

 © 2025 DJI រក្សាសិទ្ធិគ្រប់យ៉ាង។

## 5.3 ការពន្លត់ម៉ាស៊ីនភ្លើង

1. បិទរាល់ឧបករណ៍អគ្គិសនីដែលបានភ្ជាប់ទាំងអស់។
2. រំកិលកុងតាក់បិទបើកម៉ាស៊ីនទៅកាន់ទីតាំងបិទ ហើយម៉ាស៊ីនភ្លើងនឹងឈប់ដំណើរការ។
3. ផ្ដាច់រាល់ឧបករណ៍អគ្គិសនីដែលបានភ្ជាប់ទាំងអស់។

## 5.4 ការប្រើប្រាស់ថ្មហោះហើរឆ្លាតវៃជាប្រភពថាមពលខាងក្រៅ

- មិនចាំបាច់បញ្ឆេះម៉ាស៊ីនភ្លើងទេ។

1. ភ្ជាប់ខ្សែសាករបស់ម៉ាស៊ីនភ្លើងទៅថ្មហោះហើរឆ្លាតវៃ។ ចុច ហើយបន្ទាប់មកចុចប៊ូតុងថាមពលនៅលើថ្មឱ្យជាប់ ដើម្បីបើកថាមពលថ្ម។
2. ចុចប៊ូតុងបិទបើកម៉ាស៊ីនរបស់ម៉ាស៊ីនភ្លើងបីដងជាបន្តបន្ទាប់ទៅទីតាំងបញ្ឆេះ ដែលរន្ធ AC របស់ម៉ាស៊ីនភ្លើងនឹងផ្ដត់ផ្គង់ថាមពល AC។
3. ភ្ជាប់ឧបករណ៍អគ្គិសនីទៅរន្ធ AC របស់ម៉ាស៊ីនភ្លើង។

© 2025 DJI រក្សាសិទ្ធិគ្រប់យ៉ាង។ 

# 6 ការរក្សាទុក

អនុវត្តតាមជំហានខាងក្រោមសម្រាប់ការរក្សាទុក ប្រសិនបើម៉ាស៊ីនភ្លើងនឹងមិនត្រូវបានប្រើប្រាស់លើសពី 30ថ្ងៃ។

1. មុនធ្វើការរក្សាទុក សូមបញ្ឆេះម៉ាស៊ីនភ្លើងហើយទុកឱ្យវាដំណើរការរយៈពេលពីប្រាំទៅដប់នាទីដើម្បីកម្ដៅម៉ាស៊ីន។ បន្ទាប់មក ពន្លត់ម៉ាស៊ីនភ្លើងដើម្បីបង្ហូរប្រេងម៉ាស៊ីនចេញ។
2. ទាញទុយោបង្ហូរប្រេងម៉ាស៊ីនចុះក្រោម ហើយបើកគម្របតាមទិសបញ្ច្រាសទ្រនិចនាឡិកា ហើយបង្ហូរប្រេងម៉ាស៊ីនទាំងអស់ចេញ។

⚠ • ដើម្បីចៀសវាងការរលាក សូមកុំប៉ះប្រេងម៉ាស៊ីនដែលក្ដៅ។

3. ដំឡើងទុយោបង្ហូរប្រេងម៉ាស៊ីននៅនឹងកន្លែង ហើយបង្វិលមួកតាមទ្រនិចនាឡិកាដើម្បីរឹតបន្តឹងវា។
4. ដោះប៊ូឡុងបង្ហូរឥន្ធនៈនៅបាតធុងឥន្ធនៈ បង្ហូរឥន្ធនៈចេញដោយប្រើជីឡាវ ហើយរក្សាទុកឥន្ធនៈនៅក្នុងដបសម្រាប់រក្សាទុកឥន្ធនៈ ដើម្បីជៀសវាងកុំឱ្យឡើងកករ។ ដំឡើងប៊ូឡុងបង្ហូរឥន្ធនៈទៅកន្លែងដើមវិញបន្ទាប់ពីឥន្ធនៈត្រូវបានបង្ហូរចេញអស់។ សម្អាតជីឡាវ ហើយជូតវាដោយប្រើក្រណាត់ស្ងួតមុនពេលរក្សាទុក។
5. ដោះខ្ចៅដែលធ្វើឱ្យទុយោប្រេងដែលមានសម្ពាធខ្ពស់មានសុវត្ថិភាព។ ដកទុយោចេញ ហើយបង្ហូរឥន្ធនៈខាងក្នុង។ ដំឡើងបំពង់នៅនឹងកន្លែង។
6. ដាក់ម៉ាស៊ីនភ្លើងនៅកន្លែងត្រជាក់ ស្ងួត និងមានអនាម័យ។

 © 2025 DJI រក្សាសិទ្ធិគ្រប់យ៉ាង។

# 7 ការដឹកជញ្ជូន

ដើម្បីចៀសវាងការរលាក ឬឆេះសម្ភារៈងាយឆាបឆេះ ប្រសិនបើម៉ាស៊ីនភ្លើងបាននិងកំពុងដំណើរការ សូមរង់ចាំរយៈពេល 15 នាទី ដើម្បីទុកឱ្យវាត្រជាក់មុនពេលផ្លាស់ទីវាទៅក្នុងយានយន្តដឹកជញ្ជូន។ ត្រូវប្រាកដថាម៉ាស៊ីនភ្លើងមានលំនឹងក្នុងអំឡុងពេលដឹកជញ្ជូនដើម្បីចៀសវាងការកំពប់។

© 2025 DJI រក្សាសិទ្ធិគ្រប់យ៉ាង។ 

# 8 ការថែទាំ

សូមស្កេនកូដ QR នៅលើផុងឥន្ធនៈដើម្បីមើលវីដេអូបង្រៀន ឬមើលស្លាក និងស្ទីកគ័រនៅលើម៉ាស៊ីនភ្លើងសម្រាប់ការណែនាំអំពីការថែទាំ។ ត្រួតពិនិត្យ និងថែទាំម៉ាស៊ីនភ្លើងជាប្រចាំ ដើម្បីរក្សាវាឱ្យស្ថិតនៅក្នុងស្ថានភាពល្អ។

## 8.1 ការជូនដំណឹងអំពីសុវត្ថិភាពថែទាំ

- មុនពេលធ្វើការថែទាំ សូមពន្លត់ម៉ាស៊ីនភ្លើង ផ្តាច់រាល់ឧបករណ៍អគ្គិសនី និងថ្មទាំងអស់ ហើយទុកឱ្យម៉ាស៊ីនភ្លើងត្រជាក់ទាំងស្រុង។
- ធ្វើការថែទាំម៉ាស៊ីនភ្លើងនៅទីកន្លែងដែលស្អាត ស្ងួត និងមានលំនឹង។ ត្រូវប្រាកដថាម៉ាស៊ីនភ្លើងមិនអាចផ្លាស់ទីដោយចៃដន្យបាននោះទេ។
- សូមអានសៀវភៅណែនាំសម្រាប់អ្នកប្រើប្រាស់មុនពេលប្រតិបត្តិការ ហើយត្រូវប្រាកដថាអ្នកមានរាល់សម្ភារៈ និងជំនាញដែលចាំបាច់ទាំងអស់។
- ត្រូវប្រុងប្រយ័ត្នបំផុតនៅពេលប្រើប្រាស់ម៉ាស៊ីនភ្លើងនៅជិតឥន្ធនៈ ដើម្បីកាត់បន្ថយភាពអាចកើតមានគ្រោះថ្នាក់អគ្គិភ័យ ឬការផ្ទុះ។ សូមប្រើប្រាស់សារធាតុរំលាយដែលមិនងាយឆាបឆេះដើម្បីសម្អាតផ្នែកនានា។ សូមកុំប្រើឥន្ធនៈដើម្បីលាងសម្អាត។ រក្សាទុកផ្នែកដែលមានឥន្ធនៈនៅឱ្យឆ្ងាយពីកន្ទុយបារី ផ្កាភ្លើង និងភ្លើង។

## 8.2 កាលវិភាគថែទាំ

សូមអនុវត្តតាមកាលវិភាគថែទាំនៅក្នុងតារាងខាងក្រោម។ ភាពញឹកញាប់នៃការថែទាំគួរតែត្រូវបានបង្កើន ប្រសិនបើម៉ាស៊ីនភ្លើងដំណើរការនៅក្នុងមជ្ឈដ្ឋានដែលមានដីហុយ ឬមជ្ឈដ្ឋានមិនស្អាតផ្សេងទៀត។

ទាក់ទងឈ្មួញដែលមានការអនុញ្ញាត ឬផ្នែកជំនួយផ្លូវការ ដើម្បីអនុវត្តចំណុចថែទាំដែលមានដាក់សញ្ញាផ្កាយ។ សម្រាប់ចំណុចថែទាំផ្សេងទៀតដែលមិនមានរួមបញ្ចូលនៅក្នុងឯកសារនេះ សូមទាក់ទងឈ្មួញដែលមានការអនុញ្ញាត ឬផ្នែកជំនួយផ្លូវការ។

 © 2025 DJI រក្សាសិទ្ធិគ្រប់យ៉ាង។

| ទំនិញ | | ការប្រើប្រាស់នីមួយៗ | 10H | 20H | 50H | 100H | 300H / 1 ឆ្នាំ |
|---|---|---|---|---|---|---|---|
| ប្រេងម៉ាស៊ីន | ការត្រួតពិនិត្យកម្រិត | ✓ | | | | | |
| | ប្តូរ* | | | ការប្រើប្រាស់លើកទីមួយ | ✓ | | |
| ផ្នែកតម្រងអេប៉ុង | ពិនិត្យ/សម្អាត | | ✓ | | | | |
| | ប្តូរ* | | | | | | ✓ |
| ផ្នែកតម្រងក្រដាស | ពិនិត្យ/សម្អាត | | | | ✓ | | |
| | ប្តូរ* | | | | | ✓ | |
| ឧបករណ៍ទប់ផ្កាភ្លើង | សម្អាត | | | | | | ✓ |
| ប៊ូស៊ី (ម៉ូដែល៖ F6RTC) | ពិនិត្យ/សម្អាត/ប្តូរ* | | | | | | ✓ |
| ចន្លោះវ៉ាន | កែតម្រូវ* | | | | | | ✓ |
| តម្រងក្បាលចាក់ប្រេងសន្ទះបិទបើក ស្នប់ឥន្ធនៈ | សម្អាត/ប្តូរ* | | | | | | ✓ |
| ទុយោឥន្ធនៈ | ប្តូរ* | ជារៀងរាល់ 2 ឆ្នាំ (ឬនៅពេលចាំបាច់) | | | | | |

- H មានន័យថាម៉ោងប្រតិបត្តិការ។

- ចន្លោះរយៈពេលថែទាំជារៀងរាល់ 300 ម៉ោងប្រតិបត្តិការ/1ឆ្នាំ មានន័យថាអ្នកប្រើប្រាស់គួរតែអនុវត្តការថែទាំដោយផ្អែកលើសេណារីយ៉ូមួយណាដែលកើតឡើងមុន។
- បន្ទាប់ពីរៀងរាល់ 300 ម៉ោងប្រតិបត្តិការ អ្នកប្រើប្រាស់គួតែទាក់ទងទៅកាន់ឈ្មួញដែលមានការអនុញ្ញាត ឬផ្នែកជំនួយផ្លូវការ ដើម្បីពិនិត្យ និងសម្អាតតម្រងក្បាលចាក់ប្រេងសន្ទះបិទបើក និងបង្ហូរឥន្ធនៈនៅក្នុងទុយោប្រេងដែលមានសម្ពាធខ្ពស់ និងស្នប់ឥន្ធនៈ។ បិទប៊ូឡុងក្បាលស៊ីឡាំងឡើងវិញដោយប្រើកម្លាំង 55-60 N·m។
- ការស៊ីប្រេងម៉ាស៊ីននឹងមានការកើនឡើង ប្រសិនបើប្រើប្រាស់ម៉ាស៊ីនភ្លើងនៅក្នុងមជ្ឈដ្ឋានដែលមានសីតុណ្ហភាពខ្ពស់។ ចាក់បំពេញប្រេងម៉ាស៊ីនឱ្យដល់កម្រិតកំណត់មុនពេលប្រើប្រាស់ម្តងៗ ហើយបន្ថយចន្លោះរយៈពេលនៃការប្តូរប្រេងម៉ាស៊ីនឱ្យខ្លីជាងមុន។

© 2025 DJI រក្សាសិទ្ធិគ្រប់យ៉ាង។ 

## 8.3 ការពិនិត្យមើលកម្រិតប្រេងម៉ាស៊ីន

1. ពន្លត់ម៉ាស៊ីនភ្លើង ហើយដាក់វានៅលើផ្ទៃរាប់ស្មើ។ ប្រសិនបើម៉ាស៊ីនភ្លើងទើបតែដំណើរការរួច សូមរង់ចាំយ៉ាងហោចណាស់ 15 នាទីដើម្បីឱ្យវាត្រជាក់។
2. មួលចង្កឹះជ្រលក់មើលកម្រិតប្រេងម៉ាស៊ីន ហើយជូតវាចេញជាមួយក្រណាត់ស្អាត។
3. ស៊កចង្កឹះជ្រលក់មើលកម្រិតប្រេងម៉ាស៊ីនដូចមានបង្ហាញដោយមិនបាច់មួលវាចូល។ ដកចង្កឹះជ្រលក់មើលកម្រិតប្រេងម៉ាស៊ីនចេញ ហើយពិនិត្យមើលកម្រិតប្រេង។ កុំបញ្ច្រាសចង្កឹះជ្រលក់មើលកម្រិតប្រេង។
4. បន្ថែមប្រភេទប្រេងម៉ាស៊ីនដែលត្រូវបានណែនាំឱ្យដល់ កម្រិតកំណត់ខាងលើ ប្រសិនបើកម្រិតរបស់វាស្ថិតនៅជិត ឬក្រោមសញ្ញាសម្គាល់កម្រិតកំណត់ខាងក្រោម។
5. ដំឡើងចង្កឹះជ្រលក់មើលកម្រិតប្រេងម៉ាស៊ីនហើយរឹតបន្តឹងវា។




⚠ • ការខូចខាតដល់ម៉ាស៊ីនភ្លើងដែលបណ្តាលមកពីហេតុផលដូចខាងក្រោមមិនត្រូវបានរួមបញ្ចូលក្នុងការធានាទេ៖ ការដំណើរការជាមួយប្រេងម៉ាស៊ីនទាប ការខកខានមិនប្តូរប្រេងម៉ាស៊ីនតាមកាលវិភាគថែទាំ ការប្រើប្រាស់ប្រេងម៉ាស៊ីនដែលមិនបានណែនាំ។

## 8.4 ការប្តូរប្រេងម៉ាស៊ីន

1. ដាក់ម៉ាស៊ីនភ្លើងនៅលើផ្ទៃរាបស្មើ។ បញ្ឆេះម៉ាស៊ីនភ្លើងដើម្បីកម្តៅម៉ាស៊ីនឱ្យបានបួនដប់នាទី ហើយបន្ទាប់មកពន្លត់ម៉ាស៊ីនភ្លើង។
2. ដាក់ដបមួយនៅពីក្រោមទុយោបង្ហូរប្រេងម៉ាស៊ីន។
3. ទាញទុយោបង្ហូរប្រេងម៉ាស៊ីនចុះក្រោម ហើយមួលគម្របតាមទិសបញ្ច្រាសទ្រនិចនាឡិកាដើម្បីបើក។ រង់ចាំឱ្យប្រេងហូរចេញអស់ទាំងស្រុង។
4. ដំឡើង និងដាក់ទុយោបង្ហូរប្រេងម៉ាស៊ីនទៅកន្លែងដើមវិញឱ្យ ជាប់។ មួលគម្របតាមទិសទ្រនិចនាឡិកាដើម្បីរឹតវា។
5. ដោះចង្កឹះជ្រលក់មើលកម្រិតប្រេង ហើយប្រើជីឡាវប្រេងម៉ាស៊ីនដើម្បីបន្ថែមប្រេងម៉ាស៊ីនដល់កម្រិតខ្ពស់។ ស៊កចង្កឹះជ្រលក់មើលកម្រិតប្រេងចូលវិញ ហើយមួលបិទឱ្យតឹង។

 © 2025 DJI រក្សាសិទ្ធិគ្រប់យ៉ាង។



- ទាក់ទងឈ្មួញដែលមានការអនុញ្ញាត ឬផ្នែកជំនួយផ្លូវការ ដើម្បីប្ដូរប្រេងម៉ាស៊ីន។
- ប្រេងម៉ាស៊ីនជះឥទ្ធិពលយ៉ាងសំខាន់លើសមត្ថភាពរបស់ម៉ាស៊ីន ហើយជាកត្តាចម្បងដែលកំណត់អាយុកាលប្រើប្រាស់របស់វា។ គេណែនាំឱ្យប្រើប្រាស់ប្រេងដែលត្រូវបានផលិតឡើងសម្រាប់ម៉ាស៊ីនឡានបន្ទុះបួនវគ្គ (four-stroke) និងដែលបំពេញតាម ឬលើសពីកម្រិតស្តង់ដារ SJ យោងទៅតាមចំណាត់ថ្នាក់ API។ ជាធម្មតា កម្រិតថ្នាក់ API ត្រូវបានបង្ហាញនៅលើកសម្បករវេចខ្ចប់នៃដបប្រេងម៉ាស៊ីន។ ត្រូវប្រាកដថាគេសរសេរថា SJ ឬកម្រិតថ្នាក់ខ្ពស់ជាងនេះ។ ប្រភេទប្រេងម៉ាស៊ីនដែលត្រូវបានណែនាំគឺ SJ 10W-40។
- ដើម្បីបង្ការការខូចខាតចំពោះបរិស្ថាន គេណែនាំឱ្យបិទគម្របដបដែលដាក់ប្រេងម៉ាស៊ីនដែលប្រើរួចឱ្យជាប់ ហើយឱ្យទៅមជ្ឈមណ្ឌលកែច្នៃឡើងវិញ សូមកុំចាក់ចោលប្រេងម៉ាស៊ីនដែលប្រើរួចទៅក្នុងសំណល់ក្នុងផ្ទះធម្មតា ចាក់ចោលទៅលើដី ឬទៅក្នុងលូ។

## 8.5 ការពិនិត្យ និងសម្អាតផ្នែកតម្រងខ្យល់

1. បើកគម្របតម្រងខ្យល់ ហើយដកយកផ្នែកតម្រងអេប៉ុងចេញមក។ សម្អាតផ្នែកតម្រង អេប៉ុងឱ្យបានហ្មត់ចត់ដោយប្រើភ្នាក់ងារលាងសម្អាតធម្មតា ឬទឹកក្ដៅឧណ្ឌៗ ហើយដាក់វា ហាលថ្ងៃឱ្យស្ងួត។ សម្អាតធូលីនៅក្នុងបំពង់តម្រង ហើយប្រើភ្នាក់ងារលាងសម្អាតបេនដើម្បី សម្អាតប្រេងម៉ាស៊ីននៅក្នុងគម្រប ហើយជូតវាឱ្យស្ងួត។
2. ពិនិត្យមើលថាតើផ្ទៃផ្នែកតម្រងក្រដាសសើមដោយប្រេងម៉ាស៊ីនឬអត់។ ប្រសិនបើផ្នែកតម្រងក្រដាសសើមដោយប្រេងម៉ាស៊ីន សូមទាក់ទងទៅកាន់ឈ្មួញដែលមានការអនុញ្ញាត ឬផ្នែកជំនួយផ្លូវការ ដើម្បីប្ដូរផ្នែកតម្រងក្រដាសថ្មី។ ប្រសិនបើវាមិនចាំបាច់ក្នុងការប្ដូរផ្នែកតម្រងក្រដាសថ្មីទេនោះ គោះវាថ្នមៗនៅលើដី ដើម្បីរលាក់ធូលី និងកម្ទេចកម្ទីចេញ។ សម្អាតធូលីនៅក្នុងបំពង់តម្រង ហើយប្រើភ្នាក់ងារលាងសម្អាតបេន ដើម្បីសម្អាតប្រេងម៉ាស៊ីននៅក្នុងគម្រប ហើយជូតវាឱ្យស្ងួត។
3. ដំឡើងផ្នែកតម្រងក្រដាស និងផ្នែកតម្រងអេប៉ុងទៅក្នុងតម្រងខ្យល់ រួចបិទគម្របចូលកន្លែងដើមវិញ។

© 2025 DJI រក្សាសិទ្ធិគ្រប់យ៉ាង។ 



- ប្តូរផ្នែកតម្រងអេប៉ុងចេញ ប្រសិនបើវាខូចនៅពេលសម្អាត។
- សូមកុំប្រើម៉ាស៊ីនផ្លុំខ្យល់ ឬខ្យល់ដែលបានបង្ហាប់ ដើម្បីសម្អាតផ្នែកតម្រងក្រដាស ព្រោះវាអាចនឹងបណ្តាលឱ្យខូចដល់រន្ធចូលនៃផ្នែកនោះ។
- សូមប្រាកដថាអ្នកបានដំឡើងផ្នែកតម្រងខ្យល់ទាំងអស់ និងគម្របក្រោយនៅនឹងកន្លែងឡើងវិញ។

## 8.6 លាងសម្អាតឧបករណ៍ទប់ផ្កាភ្លើង

1. ប្រើប្រាស់ទួរណឺវិសដើម្បីដោះខ្ចៅ និងគម្របការពារ។ យកឧបករណ៍ទប់ផ្កាភ្លើងចេញមកក្រៅ។
2. ពិនិត្យមើលឧបករណ៍ទប់ផ្កាភ្លើង។ លាងវាដោយប្រើភ្នាក់ងារលាងសម្អាតបេន ហើយដុសជម្រះវាដោយប្រើច្រាសសរសៃលួស។ ប្តូរវា ប្រសិនបើវាខូច។
3. ដំឡើងឧបករណ៍ទប់ផ្កាភ្លើងដែលត្រូវបានសម្អាត ឬថ្មី និងរឹតវីស។



## 8.7 ការពិនិត្យ សម្អាត និងប្តូរប៊ូស៊ី

1. ពន្លត់ម៉ាស៊ីនភ្លើង ហើយត្រូវប្រាកដថាវាបានប្រែជាត្រជាក់ទាំងស្រុងហើយ។
2. មួលដោះប៊ូស៊ីដោយប្រើសោដោះប៊ូស៊ីរបស់វា ហើយពិនិត្យមើលប៊ូស៊ី។ ប្តូរប៊ូស៊ីភ្លាម ប្រសិនបើអ៊ីសូឡង់ ឬកាសទ្រនាប់បិទភ្ជិតមានការបែកបាក់។
3. យកចេញនូវកំណកកាបូន ឬកំណកផ្សេងទៀតដោយប្រើច្រាសសរសៃលួសរឹង។

 © 2025 DJI រក្សាសិទ្ធិគ្រប់យ៉ាង។

4. កែសម្រួលអេឡិចត្រូតដើម្បីធ្វើឱ្យប្រាកដថាចន្លោះគឺស្ថិតនៅក្នុងកម្រិតស្តង់ដារ 0.6 ទៅ 0.8 មិល្លីម៉ែត្រ។

5. នៅពេលដំឡើងប៊ូស៊ីម្តងទៀត មួលប៊ូស៊ីទៅក្នុងម៉ាស៊ីនដោយដៃពីរទៅបីជុំ។

6. បន្តរឹតបន្តឹងដោយប្រើសោមួលប៊ូស៊ីរបស់វា។




⚠

- ទាក់ទងផ្នែកជំនួយផ្លូវការ ឬឈ្មួញដែលមានការអនុញ្ញាតដើម្បីថែទាំប៊ូស៊ី។
- កម្លាំងបង្វិលជុំដែលត្រូវបានណែនាំគឺ 20-25 N·m។ ប៊ូស៊ីដែលរលុងធ្វើឱ្យម៉ាស៊ីនឡើងកម្ដៅ ប៉ុន្តែការរឹតប៊ូស៊ីតឹងពេកនឹងធ្វើឱ្យ ខ្ទួករណ្ដៅនៅក្នុងម៉ាស៊ីន។
- ម៉ូដែលប៊ូស៊ីដើមគឺ F6RTC។ ការដំឡើងប្រភេទប៊ូស៊ីខុស នឹងធ្វើឱ្យខូចម៉ាស៊ីន។
- ដើម្បីធានាប្រតិបត្តិការត្រឹមត្រូវនៃម៉ាស៊ីន ត្រូវប្រាកដថាចន្លោះប៊ូស៊ីគឺត្រឹមត្រូវ ហើយគ្មានកំណក។

© 2025 DJI រក្សាសិទ្ធិគ្រប់យ៉ាង។ 

# 9 លក្ខណៈបច្ចេកទេស

ចូលទៅកាន់គេហទំព័រខាងក្រោម ដើម្បីទទួលបានសេចក្ដីលម្អិត។

https://ag.dji.com/t100/specs


© 2025 DJI រក្សាសិទ្ធិគ្រប់យ៉ាង។

ទំនាក់ទំនង
**ផ្នែកជំនួយរបស់ DJI**

ខ្លឹមសារនេះអាចផ្លាស់ប្តូរដោយមិនចាំបាច់ជូនដំណឹងជាមុន។
**ទាញយកកំណែប្រែថ្មីបំផុតពី**

https://ag.dji.com/t100/downloads

ប្រសិនបើអ្នកមានសំណួរនានាអំពីឯកសារនេះ សូមទាក់ទង DJI ដោយផ្ញើសារទៅកាន់ **DocSupport@dji.com**។

DJI និង AGRAS គឺជាពាណិជ្ជសញ្ញារបស់ DJI។
សិទ្ធិថតចម្លង © 2025 DJI រក្សាសិទ្ធិគ្រប់យ៉ាង។